00157023

**Declassified to Public**
**06 September 2012**

D25/3/2

Extraordinary Chambers in the Courts of Cambodia

**Kingdom of Cambodia**
Nation Religion King

បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម
Certified Copy/Copie Conforme
ថ្ងៃទី(On/Le)..28...ខែ(Month/Mois).Dec
ឆ្នាំ (Year/Année).......2007.................
ក្រឡាបញ្ជី/ Greffier ..UCH ARUN...

ក្រឡាបញ្ជីនៃសហចៅក្រមស៊ើបអង្កេត នៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា

ជម្រាបមក

**-ឈ្មោះ** ជុំ ម៉ី

**-អាស័យដ្ឋាន:** សមាគម អាដហុក ផ្ទះលេខ៣ ផ្លូវ១៥៨ សង្កាត់បឹងរាំង ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ

**-អ៊ីម៉េល:** adhoc@forum.org.kh

**-កាលបរិច្ឆេទនៃការទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដោយក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត:** ០៨ វិច្ឆិកា ២០០៧

**-លេខសំណុំរឿងយោង:** 001/18-07-2007-ECCC-OCIJ និង 002/19-09-2007-ECCC-OCIJ

**កម្មវត្ថុ៖ ស្ថានភាពនៃការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋវេណីរបស់លោក-លោកស្រី**

ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក-លោកស្រី ត្រូវបានទទួលដោយក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេតរួចហើយ កាលពីថ្ងៃខែឆ្នាំខាងលើ ហើយ ត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងយោងលេខ **001/18-07-2007-ECCC-OCIJ** ក្រោមលេខ **D25/3** នៅថ្ងៃដដែលផងដែរ។ ក្រោយពីការិយាល័យសហចៅក្រមស៊ើបអង្កេតបានពិនិត្យលើពាក្យសុំរបស់លោក-លោកស្រី លោក-លោកស្រី ត្រូវបានជូនដំណឹងតាមរយៈសមាគមអាដហុក អំពីលទ្ធភាពចូលរួមនៅក្នុងការស៊ើបអង្កេតរបស់តុលាការមួយផ្សេងទៀត។ តាមរយៈការពិនិត្យលើចម្លើយតបរបស់លោក-លោកស្រី ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក-លោកស្រី ត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងយោងលេខ **002/19-09-2007-ECCC-OCIJ** ក្រោមលេខ **D22/7** នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧ ផងដែរ។



ORIGINAL DOCUMENT
RECEIVED ON 28/12/2007
AT 11:30
BY UCH ARUN
ACTING CASE FILE OFFICER


សហចៅក្រមស៊ើបអង្កេត * E.C.C.C * INVESTIGATING JUDGES GREFFIER * CO-JUGES D'INSTRUCTION * C.E.T.C

00157024

D25/3/2

ហេតុដូច្នេះ លើកលែងតែមានសេចក្តីសម្រេចផ្លាស់ប្តូរនៅពេលក្រោយរបស់សហចៅក្រមស៊ើបអង្កេត (សូមអានកថាខ័ណ្ឌទី ២) លោក-លោកស្រី នៅពេលនេះ ត្រូវបានចាត់ទុកជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងដំណើរការស៊ើបអង្កេតរបស់តុលាការទាក់ទិននឹងរឿងក្តីទាំងពីរនេះ។

សូមរំលឹកថា នៅគ្រប់ពេលនៃដំណើរការស៊ើបអង្កេតរបស់ខ្លួន សហចៅក្រមស៊ើបអង្កេត អាចធ្វើសេចក្តីសម្រេចផ្លូវការមួយទាក់ទិននឹងពាក្យសុំរបស់លោក-លោកស្រី ដែលអាចជា ការសម្រេចយល់ព្រម ឬបដិសេធ ប្រសិនបើសហចៅក្រមស៊ើបអង្កេតពិចារណាឃើញថា លោក-លោកស្រី មិនមែនជាជនរងគ្រោះ ឬថាលក្ខណៈវិនិច្ឆ័យទាំងឡាយដែលកំណត់ដោយវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ មិនត្រូវបានបំពេញ។ សេចក្តីសម្រេចបែបនេះ គឺបើកឱ្យធ្វើបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។

លោក-លោកស្រី ក៏ត្រូវដឹងផងដែរថា តាមរយៈការចូលរួមក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី លោក-លោកស្រី អាចដឹងអំពីព័ត៌មានសម្ងាត់នានាដែលមាននៅក្នុងសំណុំរឿង។ មានតែចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) ប៉ុណ្ណោះ ដែលអាចសម្រេចផ្តល់ព័ត៌មានទាំងនោះជាសាធារណៈ។ លោក-លោកស្រី មានកាតព្វកិច្ចរក្សាការសម្ងាត់នៃការស៊ើបអង្កេតរបស់តុលាការ ដោយមិនត្រូវលាតត្រដាងព័ត៌មានសម្ងាត់ទាំងនេះឡើយ លើកលែងតែព័ត៌មានផ្ទាល់ខ្លួនណាដែលលោក-លោកស្រី បានផ្តល់ជូនចៅក្រមនៅក្នុងការដាក់ពាក្យសុំរបស់លោក-លោកស្រី។

ប្រសិនលោក-លោកស្រី ត្រូវការការណែនាំបន្ថែម ទាក់ទិននឹងការចូលរួមរបស់លោក-លោកស្រី នៅក្នុងនីតិវិធីតុលាការ សូមធ្វើទំនាក់ទំនងមកកាន់អង្គភាពគាំពារជនរងគ្រោះ។ វិធាន និងសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក. អាចពិគ្រោះ និងថតចម្លងទុកបាន ពីគេហទំព័រនៃអង្គភាពគាំពារជនរងគ្រោះ (www.eccc.gov.kh)។

សូមលោក-លោកស្រី ទទួលនូវការរាប់អានអំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧

ក្រឡាបញ្ជីសហចៅក្រមស៊ើបអង្កេត

LY Chantola [illegible]